# សុន្ទរកថា

## សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ថ្លែងក្នុងឱកាសពិធីសម្ពោធបើកការដ្ឋានស្ថាបនាស្ពានឆ្លងកាត់ ទន្លេមេគង្គ

( កំពង់ចាម ថ្ងៃ ពុធ ទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ )

- *សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណព្រះអង្គ ជាទីសក្ការៈ*
- *ឯកឧត្តម លោកជំទាវ ឯកឧត្តម ម៉ាសាកី អ៊ែហ្គូ ឯកអគ្គរាជទូត ជប៉ុន អង្គទូតទាំងអស់ ភ្ញៀវកិត្តិយសកម្ពុជា និងបរទេស លោកស្រី អស់លោកទាំងអស់*
- *បងប្អូនជនរួមជាតិទាំងឡាយជាទីគោរពស្រឡាញ់*

ថ្ងៃនេះ ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន យើងទាំងអស់គ្នាមានកិត្តិយសប្រារព្ធពិធីសម្ពោធបើកការដ្ឋានស្ថាបនាស្ពានឆ្លងកាត់ទន្លេមេគង្គ ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជាទាំងអស់ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន ព្រមទាំងឯកឧត្តមឯកអគ្គរាជទូតជប៉ុន ដែលបានធ្វើឱ្យកើតឡើងនូវជំនួយដ៏ថ្លៃថ្លានេះសំរាប់កម្ពុជា ។

ការដ្ឋានដែលយើងសម្ពោធនៅថ្ងៃនេះ ត្រូវបានសិក្សាលើទីកន្លែងត្រូវស្ថាបនាស្ពានចំនួន ៣ កន្លែងគឺនៅអ្នកលឿង ព្រែកតាមាក់ និងកំពង់ចាម។ ក្រោយការសិក្សាដំណាក់កាលទី ១ ដើម្បីរកឱ្យឃើញនូវប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់បំផុត បានបង្ហាញឱ្យឃើញថា ទីតាំងដែលយើងកំពុងដំណើរការសម្ពោធបើកការដ្ឋាននាថ្ងៃនេះ ជាទីតាំងមួយដែលសមស្របបំផុត ។ ដំណាក់កាលទី ២ នៃការសិក្សាស្ថាបនាស្ពាន គឺការសិក្សានៅទីតាំងដែលត្រូវបានជ្រើសរើសនេះ ដើម្បីធ្វើឱ្យចេញនូវគំរោងប្លង់ជាក់ស្តែងដែលស្ពាននេះត្រូវស្ថាបនាដោយគ្រោងអស់ថវិកា ចំនួន ៦.៣៩២ លានយ៉េនជប៉ុន ហើយចាប់តាំងពីថ្ងៃបើកការដ្ឋាននេះទៅស្ពានជប៉ុនទី ២ នេះ នឹងអាចបញ្ចប់នៅខែ កក្កដា ឆ្នាំ ២០០២ ខាងមុខនេះ ។

*- ឯកឧត្តម លោកជំទាវ លោកស្រី និងអស់លោកទាំងអស់*

ចាប់តាំងពីថ្ងៃនេះទៅ ប្រជាជនកម្ពុជានៅទូទាំងប្រទេស នឹងទទួលឲ្យវាក្យថ្មីមួយទៀតសំរាប់បេះដូងរបស់ខ្លួន គឺស្ពានជប៉ុនទី ២ ។ ពាក្យស្ពានជប៉ុនទី ២ មានអត្ថន័យជាច្រើនសំរាប់វិស័យគមនាគមន៍ក្នុងប្រទេស និងក្នុងតំបន់សំរាប់វិស័យសេដ្ឋកិច្ច និងទីផ្សារ ។ ប៉ុន្តែអត្ថន័យដ៏ពិសេស និងយោយចំពោះសំរាប់ប្រជាជនកម្ពុជា គឺជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា នឹងត្រូវបានលើកស្ទួយថែមទៀតមិនខុសពីមន្ត្រីរាជការដែលត្រូវបានឡើងប្រាក់បៀវត្សនោះទេ ។ ប្រជាជនគ្មានប្រាក់បៀវត្សទេ ហើយជីវភាពរបស់ប្រជាជន នឹងត្រូវបានលើកកំពស់ថែមទៀតក៏បានមួយចំណែកយ៉ាងសំខាន់មកពីស្ពានជប៉ុនទី ២ នេះ និងបណ្តាញផ្លូវថ្នល់នានាផ្សេងទៀតដែលបានកសាង និងកំពុងកសាងនេះផងដែរ ។ យ៉ាងដូច្នេះហើយតាំងតែពីឆ្នាំ ១៩៩៣ មក ប្រទេសជប៉ុនបានផ្តល់ជំនួយឥតសំណងយ៉ាងសំខាន់ជាងគេដើម្បីជួយអភិវឌ្ឍន៍កម្ពុជា ជប៉ុនគឺជាគំរូសំរាប់កិច្ចការនិពន្ធមួយទាន់ល្អបំផុត ។

ឆ្លៀតក្នុងឱកាសដ៏ល្អប្រពៃនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមអំពាវនាវស្នើសុំជំនួយឥតសំណងពីគ្រប់ប្រទេសមិត្តភក្តិជិតឆ្ងាយទាំងអស់ រាប់ទាំងពីប្រទេសនានាក្នុងតំបន់ផង ហើយគឺជំនួយនេះហើយដែលនឹងអាចជួយឱ្យកម្ពុជាអភិវឌ្ឍន៍ទៅមុខយ៉ាងល្អប្រសើរ ។ កម្ពុជាបានខិតខំសំរេចការផ្សះផ្សា និងបង្រួបបង្រួមជាតិ ដែលនោះគឺជាប្រភពនៃការនាំមកនូវសន្តិភាពរឹងមាំ និងយូរអង្វែង ។ កម្ពុជាបានខិតខំធ្វើឱ្យមាន ស្ថេរភាព ដែលនោះគឺជាកត្តាមិនអាចខ្វះបានដើម្បីធ្វើការអភិវឌ្ឍន៍ និងកសាងជាតិ ។ ទាំងនេះអាចឆ្លុះបញ្ចាំងឱ្យឃើញថា ការអភិវឌ្ឍន៍ប្រទេស និងសំណូមពរសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ការបង្រួញចន្លោះគម្លាតរវាងទីក្រុង និងជនបទ បញ្ហាជីវភាពរស់នៅ គឺជាអាទិភាពទី ១ របស់កម្ពុជា សម និងរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ដែលមានកម្មវត្ថុដ៏ចម្បងគឺសេដ្ឋកិច្ចនេះឯង ។ សម្លេងទាមទាររបស់គ្រូបង្រៀន និងបុគ្គលិកសិក្សាមួយចំនួនឱ្យតម្លើងប្រាក់បៀវត្សរួមនឹងបំណាច់ប្រាថ្នារបស់មន្ត្រីរាជការទាំងមូល កងទ័ព និងនគរបាលទាំងអស់ដែលសុទ្ធតែចង់បានជីវភាពរស់នៅមួយសមរម្យ ហើយគ្រាន់តែអ្នកទាំងនោះដែល

ភាគច្រើនលើសលុបបង្អស់ មិនបានចេញវាចារ មិនបានចេញសម្លេង តែកំពុងបាន រួមគ្នាដើម្បីដោះស្រាយជាមួយគ្នា ហើយព្រួតកម្លាំងគ្នា ដើម្បីជំរុញការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាមួយគ្នា គឺជាសក្ខីភាពមួយបង្ហាញថា សេដ្ឋកិច្ចជីវភាព គឺជាអាទិភាពទី១ ដែលរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ឱ្យបានសំរេចជោគជ័យ។

- *ឯកឧត្តម លោកជំទាវ លោកស្រី និងអស់លោកទាំងអស់*

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ជូនចំពោះរាជរដ្ឋាភិបាល និង ប្រជាជនជប៉ុន ដែលបានផ្ដល់ជំនួយឥតសំណងដ៏ធំធេងចំពោះប្រទេសកម្ពុជា ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះប្រទេសមិត្តភក្ដិជិតឆ្ងាយទាំងអស់ ដែលបាន និងកំពុងផ្ដល់ជំនួយជាច្រើនទៀត សំរាប់កម្ពុជា ។ ខ្ញុំសង្ឃឹមជឿជាក់ថា កម្ពុជានឹងទទួលបានជំនួយដ៏មានប្រសិទ្ធិភាពច្រើនថែមទៀតដើម្បីការកសាងជាតិ ។ អ្វីដែលខ្ញុំចង់បានបន្ថែមពីជប៉ុន ទោះជាជំនួយឥតសំណងក្ដី ឬការខ្ចីឥណទានដោយការប្រាក់[redacted]ក្ដី គឺដើម្បីកសាងផ្លូវថ្នល់ភ្ជាប់ពីស្ពាននេះ គឺពីទន្លេបិទទៅ ដល់ក្រចេះ ពីក្រចេះដល់ស្ទឹងត្រែង ពីស្ទឹងត្រែងដល់ព្រំដែនឡាវ ដែលតាមរយៈផ្លូវដ៏សំខាន់នេះ នឹងជួយដល់ការអភិវឌ្ឍន៍នៅទីសប្បុរី និងឥសាន្ត កម្ពុជានឹងជួយសំរួលមួយផ្នែកដល់មិត្តឡាវផងដែរ ។

ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម ម៉ាសាគី សៃតូ ឯកអគ្គរាជទូតជប៉ុន និងសូមប្រសិទ្ធិពរជូនដល់រាជរដ្ឋាភិបាល និងប្រជាជនជប៉ុន ព្រមទាំងសូមឱ្យចំណងមិត្តភាព សហប្រតិបត្តិការរវាងជប៉ុន និង កម្ពុជាស្ថិតស្ថេរចិរកាល ។

ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរជូនព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងសូមប្រសិទ្ធិពរជូនដល់ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ញ៉ើវ កិត្តិយសជាតិ និងអន្តរជាតិទាំងអស់ ព្រមទាំងជនរួមជាតិរបស់យើង សូមទទួលបាននូវពុទ្ធពរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ និងពរជ័យ ២ ប្រការថែម ទៀតគឺ អភិវឌ្ឍនៈ និង សុភមង្គល កុំបីឃ្លៀង ឃ្លាតឡើយ ៕

*សូមអរព្រះគុណ សូមអរគុណ !*